ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ : ៧២៥ សហវ/ប្រក.ពម៣

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង

ស្តីពី

កម្រៃសេវាតម្កល់ និងស្រាវជ្រាវរកលិខិតជូនដំណឹង

នៃប្រតិបត្តិការដែលមានកិច្ចធានា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើ រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ ប្រកាសអោយប្រើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយ ច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/ ០៣៥ ចុះថ្ងៃ ទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ១២៣ MOC/SM 2007 ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការបង្កើតការិយាល័យតម្កល់ប្រតិបត្តិការដែលមានកិច្ចធានា
- យោងតាមតម្រូវការចាំបាច់ដើម្បីអនុវត្តនូវមាត្រាទាំងឡាយនៅក្នុងជំពូកទី ៣ "ការតម្កល់លិខិតជូនដំណឹង" នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

## <u>សម្រេច</u>

**ប្រការ ១:** អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មយកកម្រៃលើសេវាតម្កល់ និងស្រាវជ្រាវលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានាក្នុងគេហទំព័រ (វេបសាយ) របស់ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២:** កម្រៃសេវាតម្កល់ និងស្រាវជ្រាវកលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបានកំណត់ ដូចខាងក្រោម :

| ល.រ | បរិយាយសេវា | កម្រៃសេវា |
|---|---|---|
| ១ | តម្កល់លិខិតជូនដំណឹងដំបូង លើសិទ្ធិប្រាតិភោគ ( សំរាប់រយៈពេល ៥ ឆ្នាំ) | ១០.០០០ រៀល |
| ២ | តម្កល់វិសោធនកម្មលើលិខិតជូនដំណឹង ( មួយដង ) | ១០.០០០ រៀល |
| ៣ | តម្កល់លិខិតសុំបន្ត ( សំរាប់រយៈពេល ៥ ឆ្នាំ) | ១០.០០០ រៀល |
| ៤ | តម្កល់លិខិតសុំកែតម្រូវ ( មួយដង ) | ១០.០០០ រៀល |
| ៥ | តម្កល់លិខិតសុំបញ្ចប់ ( មួយដង) | ១០.០០០ រៀល |
| ៦ | សេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ ( មួយដង ) | ១០.០០០ រៀល |

ដោយឡែក ចំពោះការសុំតម្កល់សិទ្ធិឃាត់ទុកពីសំណាក់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល គឺមិនគិតកម្រៃឡើយ ។

**ប្រការ ៣:** ក- ការប្រមូលកម្រៃសេវា ពីសំណាក់អ្នកប្រើប្រាស់សេវារបស់ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានាត្រូវធ្វើឡើងតាមរយៈធនាគារពាណិជ្ជ ដែលជ្រើសរើសដោយក្រសួងពាណិជ្ជកម្ម ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវចុះកិច្ចសន្យាជាមួយធនាគារពាណិជ្ជ ដែលបានជ្រើសរើសសម្រាប់សេវានោះ ហើយត្រូវផ្សាយឈ្មោះធនាគារ នៅលើគេហទំព័រ (វេបសាយ) របស់ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា ។ ក្រសួងពាណិជ្ជកម្ម (ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា) ត្រូវបើកគណនីមួយនៅធនាគារដែលបានចុះកិច្ចសន្យាជាមួយដើម្បីទទួលប្រាក់កម្រៃពីសេវានេះ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គ- ធនាគារពាណិជ្ជ ដែលបានចុះកិច្ចសន្យាជាមួយក្រសួងពាណិជ្ជកម្ម ត្រូវបង្វែរទឹកប្រាក់ចំណូលរៀងរាល់ ៣ (បី) ខែម្តង ពីគណនីរបស់ ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា នៃក្រសួងពាណិជ្ជកម្ម ទៅគណនីចរន្តថវិការដ្ឋជាប្រាក់រៀលលេខ 0100-39.1211-T001 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា បន្ទាប់ពីបានកាត់កម្រៃសេវាធនាគាររួចហើយ ដូចមានចែងក្នុងកិច្ចសន្យា ។

**ប្រការ ៤ :** ចំណូលពីសេវានេះ ត្រូវកត់ត្រានៅក្នុង ជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ នៃ មាតិកាថវិកាទូទៅរបស់រដ្ឋ ។ ក្រសួងពាណិជ្ជកម្មត្រូវធ្វើរបាយការណ៍ចំណូលពីសេវានេះជារៀង រាល់ត្រីមាស មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ។

**ប្រការ ៥ :** ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ចំពោះការគ្រប់គ្រងការប្រមូលចំណូលនេះ នឹងត្រូវរៀបចំ ប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៦ :** គ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវ ទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧ :** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ចាម ប្រសិទ្ធ

__ចម្លងជូន :__

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន និង សាលាខេត្ត-ក្រុង
  " ដើម្បីជូនជ្រាប និង ផ្សព្វផ្សាយ "
- ដូចប្រការ ៦
  "ដើម្បីអនុវត្ត"
- រាជកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ និង កាលប្បវត្តិ